Disability Rights California

*California's protection & advocacy system*
*Toll-Free (800) 776-5746*

# តើករណីលើកលែងរបស់ Medi-Cal សម្រាប់មេរោគអេដស៍ និងជំងឺអេដស៍ អាចជួយអ្វីអ្នកបានខ្លះដើម្បីឲ្យអ្នកទទួលបានការថែទាំដែលអ្នកត្រូវការនៅផ្ទះ

*កែសម្រួលជាថ្មី នៅខែសីហា ឆ្នាំ* **2017, Pub. #5435.06 Cambodian**

តើកម្មវិធីករណីលើកលែងរបស់ **Medi-Cal** សម្រាប់មេរោគអេដស៍ និងជំងឺអេដស៍គឺជាអ្វី**?**

កម្មវិធីករណីលើកលែងរបស់ Medi-Cal សម្រាប់មេរោគអេដស៍ និងជំងឺអេដស៍ (¡¡±ករណីលើកលែងសម្រាប់ជំងឺអេដស៍¡¨) ផ្តល់ជូននូវការគ្រប់គ្រងករណី និងសេវាថែទាំដោយផ្ទាល់ដល់បុគ្គលដែលមានមេរោគអេដស៍/ជំងឺអេដស៍ ជំនួសឲ្យការថែទាំនៅមន្ទីរពេទ្យ ឬការចូលសម្រាកពេទ្យ។ អ្នកប្រើប្រាស់សេវានេះដើម្បីជួយដល់អ្នកឲ្យបានសម្រាកនៅផ្ទះ ឬចេញពេលមន្ទីរព្យាបាលទៅសម្រាកនៅផ្ទះ។

តើអ្នកណាខ្លះដែលមានសិទ្ធិទទួលបានសេវានេះ**?**

បុគ្គលដែលមានសិទ្ធិទទួលបានសេវានេះ ត្រូវតែះ

- មានរោគវិនិច្ឆ័យជាលាយលក្ខណ៍អក្សរអំពីមេរោគអេដស៍ ឬអេដស៍ ពីអ្នកផ្តល់ការថែទាំចម្បងរបស់គាត់/នាង និង
- មានស្ថានភាពសុខភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើឲ្យការថែទាំនៅផ្ទះមានភាពសមស្រប និង
- មានសិទ្ធិទទួលបាន Medi-Cal នៅកាលបរិច្ឆេទនៃការចុះឈ្មោះ និងនៅខែនីមួយៗបន្ទាប់ពីនោះ និង

- ត្រូវបានបញ្ជាក់ថាបានបំពេញតាមកម្រិតនៃការថែទាំនៅមន្ទីរព្យាបាល ឬខ្ពស់ជាងនេះ និងមានពិន្ទុ 60 ឬតិចជាងនេះ ដោយប្រើប្រាស់ឧបករណ៍វាយតម្លៃអំពីកម្រិតនៃសមត្ថភាពក្នុងការគិត និងសមត្ថភាពក្នុងការធ្វើសកម្មភាពនៃការរស់នៅប្រចាំថ្ងៃ។

តើសេវាប្រភេទណាខ្លះដែលអ្នកអាចស្វែងរកបាននៅក្រោមករណីលើកលែងនេះ**?**

- ការគ្រប់គ្រងករណីដោយគិលានុបដ្ឋាក-យិកា និងបុគ្គលិកសង្គមកិច្ច
- សេវាមេផ្ទះនានា ដូចជាការរៀបចំម្ហូបអាហារ និងការថែទាំផ្ទះជាទៀងទាត់ ការទិញគ្រឿងទេស។ល។
- ការថែទាំផ្ទាល់ខ្លួន
- ការសម្របផ្លូវកាយបន្តិចបន្តួចនៅផ្ទះ ដូចជា ផ្លូវជម្រាលរបារសម្រាប់ចាប់ ការពង្រីងច្រកទ្វារចេញចូល។ល។
- បរិក្ខារវេជ្ជសាស្ត្រតាមឯកទេស/សម្ភារផ្គត់ផ្គង់ផ្នែកវេជ្ជសាស្ត្រ
- ការថែទាំដែលមានជំនាញ – RN/LVN
- ការព្យាបាលដោយពេទ្យចិត្តសាស្ត្រ
- ជំនួយផ្នែកហិរញ្ញវត្ថុសម្រាប់កុមារ/ទារកដែលស្ថិតក្រោមការថែទាំនៃការចិញ្ចឹម
- ការប្រឹក្សាយោបល់អំពីចំណីអាហារ
- ការដឹកជញ្ជូនសម្រាប់ការព្យាបាលជំងឺដែលមិនបន្ទាន់
- ម្ហូបអាហារនានាត្រូវបានដឹកជញ្ជូនទៅកាន់ផ្ទះរបស់អ្នក

ព័ត៍មានបន្ថែមៈ

សេវានានានៃការលើកលែងការព្យាបាលជំងឺអេដស៍នៅមន្ទីរព្យាបាលត្រូវបានផ្តល់ជូនអតិថិជនដោយឥតគិតថ្លៃ ប៉ុន្តែការចែករំលែកសោហ៊ុយរបស់ Medi-Cal ត្រូវតែបំពេញតាមការចែករំលែកសោហ៊ុយនោះសម្រាប់ខែនីមួយៗ ដើម្បីមានសិទ្ធិទទួលបានសេវានានា។ មានការដាក់កំហិតលើសោហ៊ុយចំនួន **$25,727** ក្នុងមួយឆ្នាំ ដែលមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2017។

បុគ្គលទាំងឡាយមិនអាចចុះឈ្មោះនៅក្នុង ឬទទួលបានសេវានានាពីកម្មវិធីណាមួយក្នុងចំណោមកម្មវិធីនានាដូចខាងក្រោម នៅក្នុងពេលតែមួយនោះទេៈ កម្មវិធីថែទាំអ្នកជំងឺដំណាក់កាលចុងក្រោយរបស់ Medi-Cal; សេវាគ្រប់គ្រងករណីនៅក្នុងផែនការរបស់រដ្ឋ; ការគ្រប់គ្រងករណីដែលត្រូវបានកំណត់គោលដៅដើម្បីផ្តល់សេវាបន្ថែមនៅក្នុងការលើកលែងការព្យាបាលអេដស៍

នៅមន្ទីរព្យាបាល ឬករណីលើកលែងនៃសេវាថែទាំនៅផ្ទះ និងសេវាថែទាំដែលមានមូលដ្ឋាននៅតាមសហគមន៍ណាមួយផ្សេងទៀតរបស់ Medi-Cal។

បុគ្គលទាំងឡាយអាចត្រូវបានចុះឈ្មោះនៅក្នុងកម្មវិធីថែទាំអ្នកជំងឺដំណាក់កាលចុងក្រោយរបស់ Medicare នៅក្នុងពេលតែមួយបាន។

ទីភ្នាក់ងារនានានៃការលើកលែងការព្យាបាលជំងឺអេដស៍នៅមន្ទីរព្យាបាល អាចផ្តល់ព័ត៌មានបន្ថែមដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបាន និងសេវានានា នៃកម្មវិធីនេះ ការចុះឈ្មោះចូលរួម និងការផ្តល់ជូនដោយផ្ទាល់នូវសេវា គ្រប់គ្រងករណីដោយគិលានុប្បដ្ឋាក-យិកា និងបុគ្គលិកសង្គមកិច្ចណាម្នាក់។ ប្រសិនបើអ្នកពុំមានសិទ្ធិទទួលបានការលើកលែងការព្យាបាលជំងឺអេដស៍នៅមន្ទីរព្យាបាលទេនោះ អ្នកអាចមានសិទ្ធិទទួលបានកម្មវិធីផ្សេងទៀត នៅក្នុងទីភ្នាក់ងារដូចគ្នានោះ ឬទីភ្នាក់ងារមេរបស់ទីភ្នាក់ងារនោះ។ សម្រាប់បញ្ជីទីភ្នាក់ងារតាមខោនធី សូមមើលនៅខាងក្រោម។ សម្រាប់ធនធានផ្សេងទៀត សូមមើល https://www.cdph.ca.gov/Programs/CID/DOA/Pages/OA_care_mcwp.aspx។

សម្រាប់ព័ត៌មានអំពីការទទួលបានការលើកលែងការព្យាបាលជំងឺអេដស៍នៅមន្ទីរព្យាបាល អ្នកអាចហៅទូរស័ព្ទទៅកាន់ទីភ្នាក់ងារនៃខោនធីរបស់អ្នក ដែលបានរៀបរាប់នៅខាងក្រោម។
ប្រសិនបើអ្នកត្រូវការព័ត៌មានអំពីការដាក់ពាក្យស្នើសុំ **Medi-Cal** នោះ អ្នកអាចចូលទៅកាន់ **http://www.dhcs.ca.gov/services/medi-cal/Pages/ApplyforMedi-Cal.aspx**

អ្នកផ្តល់ជូននូវការលើកលែងការព្យាបាលជំងឺអេដស៍នៅមន្ទីរព្យាបាល
ក្រសួងសុខាភិបាលសាធារណៈនៃរដ្ឋកាលីហ្វ័រញ៉ា
ការិយាល័យនៃសាខាថែទាំជំងឺអេដស៍ និងមេរោគអេដស៍

| ខោនធីដែលបានផ្តល់សេវានេះ | ឈ្មោះទីភ្នាក់ងារ | អាសយដ្ឋានទីភ្នាក់ងារ | លេខទូរស័ព្ទរបស់ទីភ្នាក់ងារ |
|---|---|---|---|
| Alameda | AIDS Project of the East Bay | 8400 Enterprise Way Oakland, CA 94621 | (510) 663-7979 |
| Amador, Calaveras, Tuolumne | Sierra HOPE | 1168 Booster Way Angels Camp, CA 95222 | (209) 736-6792 |
| Butte, Colusa, Glenn, Shasta, Sutter, Tehama, Trinity, Yuba | Home and Health Care Management | 1398 Ridgewood Drive Chico, CA 95973 | (530) 343-0727 |

| | | | |
|---|---|---|---|
| Contra Costa | Contra Costa County Health Services Department | 597 Center Avenue Martinez, CA 94553 | (925) 313-6740 |
| El Dorado, Nevada, Placer | Sierra Foothills AIDS Foundation | 12183 Locksley Lane Auburn, CA 95602 | (530) 889-2437 |
| Lake, Mendocino, Sonoma | Community Care Management Corporation | 301 South State Street Ukiah, CA 95481 | (707) 468-9347 |
| Los Angeles | AIDS Healthcare Foundation | 1001 North Martel Avenue, Los Angeles, CA 90046 | (323) 436-5000 |
| Los Angeles | AIDS Project Los Angeles | 611 South Kingsley Drive, Los Angeles, CA 90005 | (213) 201-1600 |
| Los Angeles | AltaMed Health Services Corporation | 5427 E. Whittier Boulevard, Los Angeles, CA 90022 | (877) 462-2582 |
| Los Angeles | Minority AIDS Project | 5149 West Jefferson Boulevard, Los Angeles, CA 90016 | (323) 936-4949 |
| Los Angeles | St. Mary Medical Center | 1045 Atlantic Avenue Long Beach, CA 90813 | (888) 509-2187 |
| Los Angeles | Tarzana Treatment Centers | 7101 Baird Avenue Reseda, CA 91335 | (888) 777-8565 |
| Orange | AIDS Services Foundation | 17982 Sky Park Circle Irvine, CA 94621 | (949) 809-5700 |
| Riverside, San Bernardino | Desert AIDS Project | 1695 North Sunrise Way, Palm Springs, CA 92262 | (760) 323-4197 |
| Sacramento, Yolo | Rx Staffing and Homecare, Inc. | 4640 Marconi Avenue Sacramento, CA 95821 | (916) 485-8200 |
| San Luis Obispo | Access Support Network | 130 Nipomo Street San Luis Obispo, CA 93401 | (805) 781-3660 |
| San Francisco | Westside Community Services | 1153 Oak Street San Francisco, CA 94117 | (415) 431-9000 |
| Santa Cruz | Santa Cruz County Health Services Agency | 1060 Emeline Avenue Santa Cruz, CA 95060 | (831) 454-4313 |
| Stanislaus | Stanislaus County Health Services Agency | 830 Scenic Drive Modesto, CA 95350 | (209) 558-7000 |
| Ventura | Ventura County Public Health Department | 3147 Loma Vista Road Ventura, CA 93003 | (805) 652-6267 |

យើងខ្ញុំចង់ដឹង ពីយោបល់លោកអ្នក! សូមបំពេញ កម្រងសំណួរអង្កេត
អំពីការផ្សព្វផ្សាយ របស់យើងខ្ញុំ ហើយប្រាប់យើងខ្ញុំ ពីយោបល់លោកអ្នកផង!

https://docs.google.com/forms/d/1d6ezTI2M5UMAWU66exLbc1SQ9wDPzvtuS3AGR4-cgwE/viewform?c=0&w=1

សម្រាប់ជំនួយផ្នែកច្បាប់ សូមហៅទូរស័ព្ទទៅកាន់លេខ 800-776-5746 ឬ បំពេញស្នើសុំទម្រង់ផ្តល់ជំនួយ។ សម្រាប់គោលបំណងផ្សេងៗទៀត សូមហៅទូរស័ព្ទទៅកាន់ 916-504-5800 (កាលីហ្វ័រញ៉ាខាងជើង); 213-213-8000 (កាលីហ្វ័រញ៉ាខាងត្បូង) ។

*សិទ្ធិរបស់ជនពិការនៃរដ្ឋកាលីហ្វ័រញ៉ាបានទទួលមូលនិធិពីប្រភពខុសៗគ្នាជាច្រើន សម្រាប់បញ្ជីអ្នកផ្តល់មូលនិធិពេញលេញ សូមចូលទៅកាន់* http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html។